**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខ: ១៧៧៧៤៩៤៧

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

បានពិនិត្យត្រឹមត្រូវ

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

ថ្ងៃ........ខែ........ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង

## ស្តីពី

## ការអញ្ជើញចូលរួមដេញថ្លៃផ្គត់ផ្គង់ សម្ភារថែទាំឧបករណ៍ និងសម្ភារបរិក្ខារបច្ចេកទេសមិនមែនពត៌មានវិទ្យា ជូនអគ្គស្នងការដ្ឋាននគរបាលជាតិ, អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម, អគ្គនាយកដ្ឋានអន្តោប្រវេសន៍, គណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ, អគ្គនាយកដ្ឋាន ភស្តុភារ និងហិរញ្ញវត្ថុ, បណ្ឌិត្យសភានគរបាលកម្ពុជា, អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងក្រុមប្រឹក្សានីតិកម្ម

ក្រសួងមហាផ្ទៃ សូមជម្រាបជូនដំណឹងដល់បណ្តាក្រុមហ៊ុនក្នុងស្រុក (គិតទាំងសហគ្រាសឯកត្តបុគ្គល)ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា ៖ ក្រសួងមហាផ្ទៃនឹងដាក់ឱ្យដេញថ្លៃប្រកួតប្រជែងជាសាធារណៈ ដើម្បីជ្រើសរើសអ្នកផ្គត់ផ្គង់ សម្ភារថែទាំឧបករណ៍ និងសម្ភារបរិក្ខារបច្ចេកទេសមិនមែនពតិមានវិទ្យា ជូនអគ្គស្នងការដ្ឋាននគរបាលជាតិ, អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម, អគ្គនាយកដ្ឋានអន្តោប្រវេសន៍, គណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ, អគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ, បណ្ឌិត្យសភានគរបាលកម្ពុជា, អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងក្រុមប្រឹក្សានីតិកម្ម ។

ក្រសួងមហាផ្ទៃ បានរៀបចំឯកសារដេញថ្លៃ (សៀវភៅបន្ទុក) សម្រាប់ក្រុមហ៊ុនបំពេញ ដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្ម ដែលមានអាសយដ្ឋានស្ថិតនៅអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុក្រសួងមហាផ្ទៃ ចាប់ពីថ្ងៃទី ..១៧..... ខែ ...សីហា....... ឆ្នាំ២០១៩ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០៩៧ ៦៦ ៧ ៧ ៨៥៦) ។

ឯកសារដេញថ្លៃ (សៀវភៅបន្ទុក) ដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម ក្រសួងមហាផ្ទៃ យ៉ាងយូរបំផុតត្រឹមវេលាម៉ោង.០៩ : ០០..........នាទី ថ្ងៃទី.១១..... ខែ..តុលា.... ឆ្នាំ២០១៩ ។

ការបើកកញ្ចប់ឯកសារដេញថ្លៃ នឹងប្រព្រឹត្តទៅនៅសាលប្រជុំក្រសួងមហាផ្ទៃ វេលាម៉ោង..០៩ : ០០...នាទី ថ្ងៃទី..១១.... ខែ....តុលា... ឆ្នាំ២០១៩ ។

-ក្រុមហ៊ុនដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់ឯកសារដេញថ្លៃបានតែមួយគត់ ។

-ក្រុមហ៊ុន ដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មក្រសួងមហាផ្ទៃ ដើម្បីទិញឯកសារដេញថ្លៃ (សៀវភៅបន្ទុក) និងសាកសួរព័ត៌មាននានាដែលទាក់ទងនឹងការដេញថ្លៃនេះ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ប្រធាន គលប**

**សម្តេចក្រឡាហោម ស ខេង**

ចម្លងជូន ៖

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

"អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ"